# តើអ័ប៊ីសជានរណា ?



អ័ប៊ីស គឺជាសាសន៍លេមិន ។ នាងបានធ្វើការឲ្យស្ដេច និងម្ចាស់ក្សត្រី ។



ថ្ងៃមួយ អ័ប៊ីស បានឃើញអាំម៉ូនកំពុងបង្រៀនពួកគេអំពីព្រះយេស៊ូវគ្រីស្ទ ។ អស់អ្នកដែលបានស្ដាប់បានទទួលអារម្មណ៍ពីព្រះវិញ្ញាណយ៉ាងខ្លាំង រហូតពួកគេដួលទៅលើដី ។



អ័ប៊ីស បានជឿទៅលើព្រះយេស៊ូវគ្រីស្ទរួចហើយ ។ នាងដឹងថាព្រះចេស្ដានៃព្រះបានធ្វើឲ្យអ្នកផ្សេងទៀតដួលនៅលើដី ។



នាងបានរត់ទៅក្រៅ ហើយបានប្រាប់ប្រជាជនឲ្យមកមើលអព្ភូតហេតុដែលបានកើតឡើងចំពោះម្ចាស់ក្សត្រី និងស្ដេច ។



នាងបានជួយម្ចាស់ក្សត្រីឲ្យក្រោកឈរ ។



ស្ដេច និងម្ចាស់ក្សត្រីបានចែកចាយទីបន្ទាល់របស់ពួកទ្រង់អំពីព្រះយេស៊ូវគ្រីស្ទជាមួយអ្នកដទៃ ។ ( សូមមើល អាលម៉ា ១៩:១៦–១៧, ២៨–៣១ ) ។ ●

## ការសាកល្បងព្រះគម្ពីរ

តើនរណាបានបង្រៀនស្ដេចឡាម៉ូណៃអំពីព្រះ ? ( អាលម៉ា ១៨:២៦–២៨ )

________________

តើសាសន៍លេមិន បានហៅឈ្មោះថ្មីរបស់ពួកគេថាជាអ្វីបន្ទាប់ពីបានធ្វើតាមព្រះយេស៊ូវគ្រីស្ទ ? ( អាលម៉ា ២៣:១៧ )

________________

តើប្រជាជនបានកប់អ្វីនៅក្នុង អាលម៉ា ២៤:១៩ ?

________________

## ខ្ញុំចេះអានព្រះគម្ពីរមរមន !

បន្ទាប់ពីប្អូនអាន សូមផាត់ពណ៌ផ្នែកនៃរូបភាពនេះ ។ ប្អូនអាចអានខគម្ពីរទាំងនេះដែលស្របទៅនឹងអំណានប្រចាំសប្ដាហ៍នីមួយៗមកពីសៀវភៅ *ចូរមកតាមខ្ញុំ*បាន ។

សប្ដាហ៍ទី១ ៖ អាលម៉ា ១៩:៣៥-៣៦

សប្ដាហ៍ទី២ ៖ អាលម៉ា ២៦:១២

សប្ដាហ៍ទី៣ ៖ អាលម៉ា ៣១:៣៨

សប្ដាហ៍ទី៤ ៖ អាលម៉ា ៣៣:៤–១១



សូមសរសេរចុះអំពីរបៀបដែលប្អូនអាចជួយអ្នកដទៃរៀនអំពីព្រះយេស៊ូវ ។ ចែកចាយអ្វីដែលប្អូនបានសរសេរជាមួយយើង !